ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
លេខ....០៦២.........បទ.ស.ស.រ........

# សេចក្តីសម្រេច
# ស្តីពី
# ការបន្ថែមសមាជិកក្រុមការងារត្រួតពិនិត្យការគ្រប់គ្រងចំណូល និងផ្តល់ផ្តងបំណុលតាមបណ្តាក្រុមហ៊ុនធ្វើអាជីវកម្មលើវិស័យទូរគមនាគមន៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការងារចាំបាច់របស់ក្រសួង។

## សម្រេច

ប្រការ ១._

ចាត់តាំងលោក **ហ៊ីង លីហៃ** ប្រធាននាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសមាជិកបន្ថែមនៃក្រុមការងារត្រួតពិនិត្យការគ្រប់គ្រងចំណូល និងផ្តល់ផ្តងបំណុល តាមបណ្តាក្រុមហ៊ុនធ្វើអាជីវកម្មលើវិស័យទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លេខ ០៣៥ បទ.សសរ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤។

ប្រការ ២._

សាមីខ្លួនត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ឯកឧត្តមប្រធានក្រុមការងារ។

ប្រការ ៣._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃសេចក្ដីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៤._

អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គាធិការដ្ឋាន បញ្ញត្តិករទូរគមនាគមន៍កម្ពុជា គ្រប់នាយកដ្ឋាន និងបណ្ដាក្រុមហ៊ុនធ្វើអាជីវកម្មលើវិស័យទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសាររបស់សេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

ប្រាក់_សុខុន

**ចម្លងជូន ៖**

. ទីស្ដីការគណៈរដ្ឋមន្ត្រី
. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
. ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
« ដើម្បីជូនជ្រាប »
. ដូចប្រការ៤ « ដើម្បីអនុវត្ត »
. ឯកសារ កាលប្បវត្តិ



កាច់ជ្រុងវិថីលេខ ១៣ និង១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៨២៤៦
ទូរសារ (៨៥៥) ២៣-៤២៦៥៩១/៤២៦០០៥/៧២៤៨០៩